ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៥៤៤ ប្រ.ក

# ប្រ កា ស

## ស្តីពី
## ការកំណត់តួនាទី ភារកិច្ច និងរបៀបរបបការងារ និងរចនាសម្ព័ន្ធ នៃក្រុងប៉ោយប៉ែត ក្រុងបាវិត ក្រុងសួង ក្រុងព្រៃវែង ក្រុងព្រះវិហារ ក្រុងក្រចេះ ស្រុករុក្ខគីរី និងខណ្ឌសែនសុខ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងប្រកាសលេខ ០៣១ ប្រ.ក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត ក្រុង
- យោងប្រកាសលេខ ៣៤៨ ប្រ.ក ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០០ ស្តីពី តួនាទី ភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធ នៃ សាលាស្រុក ខណ្ឌ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## ស ម្រេ ច

**ប្រការ ១** : ត្រូវបានកំណត់តួនាទី ភារកិច្ច របៀបរបបធ្វើការងារ និង រចនាសម្ព័ន្ធរបស់ក្រុង ស្រុក ខណ្ឌបង្កើតថ្មី រួមមាន :

១-ក្រុងប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យ
២- ក្រុងបាវិត នៃខេត្តស្វាយរៀង
៣- ក្រុងសួង នៃខេត្តកំពង់ចាម
៤- ក្រុងព្រៃវែង នៃខេត្តព្រៃវែង
៥- ក្រុងព្រះវិហារ នៃខេត្តព្រះវិហារ
៦- ក្រុងក្រចេះ នៃខេត្តក្រចេះ
៧- ស្រុករុក្ខគីរី នៃខេត្តបាត់ដំបង
៨- ខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ ។

**ប្រការ ២** ៖ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ក្រុង ស្រុក ខណ្ឌដូចមានចែងនៅក្នុងប្រការ១ ខាងលើ ត្រូវបានកំណត់ដូចតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធរបស់សាលាស្រុក ខណ្ឌ ដែលបានកំណត់នៅក្នុងប្រកាសលេខ ៣៤៨ ប្រ.ក ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០០ ស្ដីពីតួនាទី ភារកិច្ច របៀបរបបការងារ និងរចនាសម្ព័ន្ធនៃសាលាស្រុក ខណ្ឌ រហូតដល់ពេលមានការកំណត់អំពីតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធថ្មី ។

**ប្រការ ៣** ៖ អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំធ្វើការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជាក់ស្ដែងក្នុងជួរគណៈអភិបាល ស្របទៅតាមចំនួនគណៈអភិបាលដែលបានកំណត់ នៅតាមសាលាក្រុង ស្រុក ខណ្ឌនីមួយៗ ។

**ប្រការ ៤** ៖ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អភិបាលរាជធានីភ្នំពេញ អភិបាលខេត្តបន្ទាយមានជ័យ អភិបាលខេត្តកំពង់ចាម អភិបាលខេត្តស្វាយរៀង អភិបាលខេត្តព្រៃវែង អភិបាលខេត្តព្រះវិហារ អភិបាលខេត្តក្រចេះ អភិបាលខេត្តបាត់ដំបង ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្ដុះបណ្ដាលវិជ្ជាជីវៈក្រសួងមហាផ្ទៃ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិនា ឆ្នាំ ២០០៩*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**កន្លែងទទួល**

- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *គ្រប់ក្រសួង ស្ថាប័ន*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចប្រការ ៤*
  *(ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*